**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៧៤៥ ព.ណ.ន.ចបព

ថ្ងៃអង្គារ ១០កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើសាមញ្ញកម្មការងារចុះបញ្ជីពាណិជ្ជកម្ម ដំណាក់កាលទី២

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូន ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលជាអ្នកគ្រប់គ្រងក្រុមហ៊ុន និងសហគ្រាសទាំងអស់មេត្តាជ្រាបថា ក្រសួងពាណិជ្ជកម្ម បានចេញប្រកាសលេខ ០៤៤ ព.ណ.ន.ចបព.ប្រក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៦ ក្នុងគោលបំណងបន្តធ្វើសាមញ្ញកម្មការងារចុះបញ្ជីពាណិជ្ជកម្ម ដំណាក់កាលទី២ តាមរយៈការសម្រួលនីតិវិធីមុខងារពាក់ព័ន្ធនឹងការងារចុះបញ្ជីពាណិជ្ជកម្ម មានជាអាទិ៍៖

១.ការឈប់ទទួលតម្កល់លក្ខន្តិកៈជាទម្រង់ក្រដាស (Hard Copy) ជំនួសវិញដោយការតម្កល់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រើប្រាស់ថ្នាល verify.gov.kh ដើម្បីបញ្ជាក់សក្ខីភាពនៃការតម្កល់

២.ការមិនតម្រូវឱ្យមានការតម្កល់ប្រាក់ក្នុងការបំពេញមុខងារ ដើម្បីប្រកបវិជ្ជាជីវៈជាលេខាធិការក្រុមហ៊ុន។ បុគ្គលគ្រប់រូបអាចត្រូវជ្រើសតាំងជាលេខាធិការក្រុមហ៊ុន លើកលែងតែមានវិសមិតភាពមុខងារ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត

៣.ការចុះបញ្ជីបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក ត្រូវធ្វើឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងរាល់ការផ្លាស់ប្តូរនាយកសាខាក្នុងស្រុក គឺមិនតម្រូវឱ្យមានការជូនដំណឹងមកក្រសួងពាណិជ្ជកម្មទៀតទេ

៤.ការបង្កើតក្រុមការងារចំពោះកិច្ច សម្រាប់ដោះស្រាយសំណូមពររបស់វិស័យឯកជនលើការងារចុះបញ្ជីពាណិជ្ជកម្ម ដើម្បីសម្រួលដល់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចរាល់ ក្នុងការស្នើសុំការធ្វើបច្ចុប្បន្នភាពការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងផ្តល់គណនី username និង password ដែលបានបាត់បង់ ឬមិនទាន់បានធ្វើបច្ចុប្បន្នភាពត្រឹមត្រូវតាមកាលកំណត់ សម្រាប់ចូលទៅប្រើប្រាស់ និងគ្រប់គ្រងគណនីព័ត៌មានក្រុមហ៊ុនដែលមានស្រាប់ ដោយមិនតម្រូវឱ្យបង់កម្រៃសេវា ជាដើម

៥.និរាករណ៍ជំពូកទី១០ នៃប្រកាសលេខ១១៧ ព.ណ.ចបព.ប្រក ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការធ្វើសាមញ្ញកម្មការងារចុះបញ្ជីពាណិជ្ជកម្ម។

ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្ម ក៏បានធ្វើបច្ចុប្បន្នភាពគេហទំព័រសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ដែលមានឈ្មោះ www.businessregistration.moc.gov.kh ក្នុងគោលបំណងពង្រឹងសុវត្ថិភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានឱ្យមានប្រសិទ្ធភាព និងស្ថិរភាព។ ទន្ទឹមនឹងនេះ មុខងារតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ នៅលើប្រព័ន្ធដែលបានធ្វើបច្ចុប្បន្នភាពនេះ ត្រូវបានកែសម្រួលឱ្យដំណើរការជាប្រក្រតី **ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។**



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ក្នុងន័យនេះ សូម ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលមានគណនីប្រើប្រាស់រួចរាល់ មេត្តាកំណត់លេខសម្ងាត់ថ្មីឡើងវិញ ដើម្បីរក្សាសុវត្ថិភាពគណនីរបស់លោកអ្នក។ ក្នុងករណី ដែលមានបញ្ហាបច្ចេកទេសក្នុងការកំណត់លេខសម្ងាត់ថ្មីឡើងវិញ និងមុខងារសេវាសាធារណៈផ្សេងៗទៀត សូមមេត្តាទំនាក់ទំនងមក នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម តាមរយៈប្រព័ន្ធទូរសព្ទសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម លេខ ១២៦៦ (សូមចុចលេខ២ សម្រាប់ព័ត៌មានលម្អិតលើការងារចុះបញ្ជីពាណិជ្ជកម្ម ការស្នើសុំការធ្វើបច្ចុប្បន្នភាពការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ និងការផ្តល់ជូនគណនី) ដើម្បីក្រុមការងារជំនាញពិនិត្យផ្តល់ព័ត៌មាន និងដំណោះស្រាយបច្ចេកទេសជូន នៅពេលចូលប្រើប្រាស់ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជ្រាបជាព័ត៌មាន។

**សូមអរគុណ!**




**ស្កេនដើម្បីទាញយកប្រកាស**
**លេខ០៤៤ ព.ណ.ន.ចបព.ប្រក**
**ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៦**

**ប្រព័ន្ធទូរសព្ទសាធារណៈ**
**ក្រសួងពាណិជ្ជកម្ម**

**1266**